# កញ្ចប់នៃសៀវភៅសម្រាប់មុខវិជ្ជាគោល
# តើអ្នកបានរៀនអ្វីខ្លះ?

ថ្នាក់ទី 2 - សិល្បៈភាសាអង់គ្លេស - លំអានអក្សរសិល្ប៍ 2.2

| ស្តង់ដារមុខវិជ្ជាស្នូល | ជាមូលដ្ឋាន ត្រង់នេះមានន័យថា កូនរបស់អ្នក ... |
|---|---|
| RL.2.2 ពិពណ៌នារឿងឡើងវិញ ល្បើកខ្លីៗ រឿងព្រេងនិទានខ្លីៗ ពីវប្បធម៌ចម្រុះ និងកំណត់សារសំខាន់មេរៀន ឬការទូន្មាន។ | បង្ហាញពីសារ មេរៀន ឬការទូន្មានដែលអ្នកនិពន្ធព្យាយាមទាក់ទងទៅកាន់អ្នកអាន។ |

## ព័ត៌មានគោលៈ

ខណៈពេលអ្នកកំពុងអានរឿងណាមួយ ជាធម្មតា រឿងនោះបង្កប់នូវសារ មេរៀន ឬការទូន្មានដែលតួអង្គបានទទួល ផ្អែកលើព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងសាច់រឿង។ នៅពេលកូនរបស់យើងធ្វើទង្វើដែលមិនសមរម្យ យើងអាចសួរពួកគេថា "តើកូនបានរៀនអ្វីខ្លះពីអ្វីដែលកូនបានធ្វើ?" គោលគំនិតដូចគ្នានេះក៏អាចប្រើប្រាស់បានចំពោះការអានផងដែរ។ កូនរបស់លោកអ្នកនឹងមើលអត្ថបទផ្សេងដើម្បីកំណត់ពីមេរៀន ការទូន្មាន ឬសារ។

**ការទូន្មាន** - មេរៀនដែលអាចរៀនពីក្នុងរឿង។

**ល្បើក** - រឿងខ្លីដែលមានតួអង្គជាសត្វចេះនិយាយដែលផ្តល់ការទូន្មាន។

**ព្រេងនិទាន** - រឿងដែលត្រូវបាននិទានតពីជំនាន់មួយទៅជំនាន់មួយទៀត។

## សកម្មភាពៈ

1. អានរឿង "ស្រមោច និងកណ្តូប" ជាមួយនឹងកូនរបស់អ្នក និងបង្ហាញពីចំណុចទូន្មាននៃល្បើកនេះ។
2. ពិភាក្សានៅត្រង់ចំណុចដែលកូនរបស់អ្នកត្រឡប់មកអានអត្ថបទឡើងវិញ ដើម្បីបញ្ជាក់ពីចម្លើយរបស់ពួកគេ។
3. ឥឡូវ អានរឿង "ទន្សាយ" និងបង្ហាញអំពីចំណុចនៃការទូន្មាន។
4. នៅពេលអ្នកអានរឿងទាំងនេះ សូមសួរកូនរបស់លោកអ្នកឲ្យស្វែងរកចំណុចទូន្មាននៅក្នុងព្រេងកថា និងល្បើកផ្សេងទៀត។

## សកម្មភាពបន្ថែមៈ

1. ចែករំលែក "រឿងរ៉ាវនៅក្នុងគ្រួសារ" ទៅកាន់កូនរបស់អ្នក។ ប្រាប់អំពីពេលដែលអ្នកបានរៀនមេរៀននៅក្នុងជីវិតរបស់អ្នក។ ឲ្យកូនរបស់អ្នកស្វែងយល់តើអ្វីគឺជាពីចំណុចទូន្មាននៅក្នុងរឿង។

## ធនធានឯកសារៈ

# រឿងស្រមោច និងកណ្តូប

ក្នុងវាលស្រែ នាថ្ងៃមួយនៃរដូវប្រាំង មានសត្វកណ្តូបមួយក្បាលកំពុងលោត ស្រែក ច្រៀងកំសាន្តយ៉ាងសប្បាយរីករាយ។ ពេលនោះ ស្រមោចមួយក្បាលក៏បានវារកាត់ និងកំពុងពាំគ្រាប់ពោតយ៉ាងសស្រាក់សស្រាំទៅដាក់ក្នុងសំបុក។

កណ្តូបបានសួរថា "ហេតុអ្វីមិនមកនិយាយលេងជាមួយខ្ញុំ បែរជាទៅធ្វើការលំបាកវេទនាយ៉ាងនោះ?"

ស្រមោចបានតបថា "ខ្ញុំកំពុងជួយសន្សំស្បៀងសម្រាប់រដូវរងារ ហើយបងកណ្តូបឯងគួរតែធ្វើដូចនេះដែរទៅ។"

កណ្តូបបាននិយាយតបថា "ចាំបាច់ខ្វល់ពីរដូវរងារធ្វើអ្វី? យើងមានស្បៀងជាច្រើនឥឡូវនេះ។" ប៉ុន្តែស្រមោចបានបន្តដំណើរ និងធ្វើការងាររបស់ខ្លួនយ៉ាងហត់នឿយតាមធម្មតា។

នៅពេលរដូវរងារចូលមកដល់ កណ្តូបគ្មានស្បៀង ហើយដឹងខ្លួនថានឹងស្លាប់ដោយអត់ឃ្លាន នៅពេលមើលឃើញស្រមោចបែងចែកគ្រាប់ពោត និងធុញ្ញជាតិចេញពីឃ្លាំង ដែលពួកគេបានប្រមូលបានក្នុងរដូវក្តៅ។ ក្រោយមកកណ្តូបក៏បានដឹងថាៈ វាជារឿងដែលល្អបំផុតក្នុងត្រៀមខ្លួនទុកជាមុនសម្រាប់តម្រូវការនាពេលខាងមុខ។

# កញ្ជ្រោងចេញទៅប្រម៉ាញ់

រឿងព្រេងរបស់លោក Georgia Tall
និពន្ធឡើងវិញដោយលោក S.E. Schlosser

នៅថ្ងៃត្រជាក់មួយនៃសទររដូវ តើអ្នកដឹងឬទេ មានកញ្ជ្រោងមួយក្បាលបានសម្រេចចិត្តចេញទៅប្រម៉ាញ់។ វាបានបង្កើតជាមិត្តជាមួយនឹងទន្សាយ កាលពីពីរ ឬបីខែមុន ហើយវាបានគិតថាវាគឺជារឿងល្អប្រសិនបើពួកគេចេញទៅប្រម៉ាញ់ជាមួយគ្នា។ ដូច្នោះ កញ្ជ្រោងក៏បានឈប់នៅកន្លែងរបស់ទន្សាយ និងបបួលទន្សាយទៅជាមួយ។

ទន្សាយបាននិយាយថា "ខ្ញុំអត់ទៅទេ បងកញ្ជ្រោង។ ខ្ញុំហត់នឿយណាស់ថ្ងៃនេះ ហើយខ្ញុំចង់សម្រាក។"

គ្មានពាក្យអ្វីដែលកញ្ជ្រោងអាចបញ្ចុះបញ្ចូលឲ្យទន្សាយផ្លាស់ប្តូរចិត្តបានឡើយ ដូច្នេះកញ្ជ្រោងក៏ចេញទៅប្រម៉ាញ់តែម្នាក់ឯង។ វាគឺជាការប្រម៉ាញ់ដែលទទួលបានផលជាអនេក។ កញ្ជ្រោងប្រម៉ាញ់បានសត្វម្រឹកពេញមួយថង់ ហើយបានធ្វើដំណើរ ហួចយ៉ាងសប្បាយរីករាយត្រឡប់មកផ្ទះវិញ។ បន្ទាប់ពីបានចំណាយពេលវេលាខ្ជិលច្រអូសនៅក្នុងសួនច្បាររបស់ខ្លួន ទន្សាយចាប់ផ្តើមឃ្លាន ក៏ស៊ីសត្វល្អិត ហើយគិតថាខ្លួនគួរតែបានទៅប្រម៉ាញ់ជាមួយនឹងកញ្ជ្រោងដែរ ពីព្រោះប្រសិនបើខ្លួនចេញទៅប្រម៉ាញ់ នោះប្រហែលជាខ្លួនទទួលបានសត្វម្រឹកជាច្រើនសម្រាប់ចម្អិនធ្វើជាអាហារបាត់ទៅហើយ។ ក្រោយមក ទន្សាយក៏បានរកនឹកឃើញគំនិត មួយ។ ប្រហែលជាវានៅតែអាចទទួលបានសត្វម្រឹកមួយចំនួន។

ទន្សាយក៏បានរត់តាមផ្លូវទៅព្រៃ និងចាំស្តាប់រកមើលកញ្ជ្រោង។ នៅពេលដែលទន្សាយបានលឺកញ្ជ្រោងហួច ពេលកំពុងដើរមកតាមផ្លូវ ទន្សាយក៏បានដេកស្តូកស្តឹងនៅលើផ្លូវ និងធ្វើពុតជាស្លាប់។ បន្តិចក្រោយមក កញ្ជ្រោងបានដើរបត់ផ្លូវកោងមួយ ក៏ប្រទះឃើញទន្សាយដ៏ធាត់មួយដេកសន្ធឹងផ្លូវ។ ទន្សាយនេះមានមាឌធំ និងធាត់ឡើងមូល។ កញ្ជ្រោងបានចំអន់លេងបន្តិច និងត្រឡប់ខ្លួនទន្សាយមើល។

យី! ទន្សាយនោះពោះឡើងកំប៉ោង! ប៉ុន្តែក្រោយមក កញ្ជ្រោងគ្រវីក្បាល និងនិយាយថា "ខ្ញុំជឿថាទន្សាយនេះងាប់យូរហើយ។ សាច់វាមិនគួរឲ្យទទួលស៊ីឡើយ។ ខ្ញុំគួរតែទុកវាចោលទីនេះវិញល្អជាង។" បន្ទាប់មកកញ្ជ្រោងក៏បន្តដំណើរតាមផ្លូវទៅមុខទៀត។

នៅពេលដែលកញ្ជ្រោងបានចាកចេញភ្លាម ទន្សាយក៏បានងើបឡើងយ៉ាងលឿន។ ទន្សាយក៏ធ្វើដំណើរតាមផ្លូវកាត់តាមវាលស្មៅ ទៅដល់ខាងមុខកញ្ជ្រោង។ បន្ទាប់មកទន្សាយក៏ដេកស្តូកនៅលើផ្លូវ និងធ្វើពុតជាស្លាប់ម្តងទៀត។ នៅពេលដែលកញ្ជ្រោងបានឃើញទន្សាយធាត់ដែលស្លាប់ទីពីរ កញ្ជ្រោងក៏សម្រេចចិត្តថា ត្រូវធ្វើអ្វីមួយចំពោះទន្សាយនេះ។ កញ្ជ្រោងបានសើចយ៉ាងសប្បាយរីករាយ និងបានដាក់ថង់ដាក់សត្វម្រឹកដ៏ធ្ងន់ក្បែរទន្សាយដែលស្លាប់នោះ និងបានរុញបញ្ចូលទន្សាយនោះទៅក្នុងថង់។ កញ្ជ្រោងក៏បាននិយាយទៅខ្លួនឯងថា "ខ្ញុំគួរតែរត់ត្រឡប់ទៅយកទន្សាយធាត់ដែលបានឃើញមុននេះ មុនពេលមានអ្នកផ្សេងយក។" កញ្ជ្រោងក៏បានទុកថង់ដ៏ធ្ងន់នោះចោល និងប្រញាប់ប្រញាល់ទៅកាន់កន្លែងដែលខ្លួនបានឃើញទន្សាយងាប់មួយទៀត។

នៅពេលចេញបាត់កញ្ជ្រោងពីក្រសែភ្នែកហើយ ទន្សាយក៏បានវារចេញពីថង់យ៉ាងលឿន និងប្រមូលយកសត្វម្រឹកពេញដៃទាំងពីរ រត់ត្រឡប់ទៅផ្ទះវិញដើម្បីស្ល។ ពីរ ឬបីនាទីក្រោយមក ទន្សាយបានឃើញកញ្ជ្រោងដើរទាំងកហឹងតាមផ្លូវមកផ្ទះរបស់ទន្សាយ។ កញ្ជ្រោងមានកំហឹងពុះកញ្ជ្រោល។ ទន្សាយបានសើច និងបានសួរកញ្ជ្រោងថា "យ៉ាងម៉េចដែរការប្រម៉ាញ់ថ្ងៃនេះ បងកញ្ជ្រោង?"

កញ្ជ្រោងបានសម្លឹងទៅកាន់ទន្សាយ ហើយនិយាយថា "មិនល្អទេ បងទន្សាយ។ សត្វម្រឹករបស់ខ្ញុំហាក់ដូចជាបានរួចអស់!" ទន្សាយក៏បានសើចចំអកដល់កញ្ជ្រោង។ "ពិតជាសំណាងមិនល្អមែន។ ប៉ុន្តែខ្ញុំមាននៅសល់សត្វម្រឹកពេញមួយថង់នៅទីនេះ។ ចុះម៉េចក៏បងមិនអង្គុយចុះ និងឆីសម្លជាមួយខ្ញុំមក?"

កញ្ជ្រោងបានស្រែកថា "អាកំហូច អញគួរតែបានធ្វើឲ្យឯងស្លាប់មែនទែនជាជាងកំប្លែងលេងជាមួយនឹងឯង!" ប៉ុន្តែទន្សាយគិតតែសើចចំអកដល់កញ្ជ្រោងរហូតទាល់តែធ្វើឲ្យកញ្ជ្រោងសើចផងដែរ។ បន្ទាប់មកពួកគេបានអង្គុយចុះ និងឆីសម្លជាមួយគ្នា។

# ប្រភពឯកសារ

- Ant and The Grasshopper

  *http://americanfolklore.net/folklore/2008/09/brer_fox_goes_hunting.html*

- Brer Rabbit

  *http://www.eastoftheweb.com/short-stories/UBooks/AntGra.shtml*